# សេវាកម្មវាយតម្លៃមុននឹងធ្វើការទទួលយក
## សេវាកម្មគាំទ្រសុខភាពផ្លូវចិត្តរបស់សហគមរដ្ឋវិចតូរីយ៉ា

សេវាកម្មវាយតម្លៃមុននឹងធ្វើការទទួលយកនឹងជួយបង្កើនមធ្យោបាយក្នុងការទទួលព័ត៌មានព្រមទាំងជួយបញ្ជូនបន្តទៅឲ្យសេវាកម្មគាំទ្រសុខភាពផ្លូវចិត្តផងដែរ។

### តើសេវាកម្មវាយតម្លៃមុននឹងធ្វើការទទួលយកមានភារកិច្ចអ្វីខ្លះ?

សេវាកម្មវាយតម្លៃមុននឹងធ្វើការទទួលយកនៃសេវាកម្មគាំទ្រសុខភាពផ្លូវចិត្ត (MHCSS) ថ្មីនេះ នឹងផ្តល់ព័ត៌មាន ព្រមទាំងជួយបញ្ជូនបន្តសម្រាប់អ្នកដែលស្វែងរកជំនួយផ្នែកសុខភាពផ្លូវចិត្ត។ សេវាកម្មនេះនឹងផ្តល់នូវ៖

- ការត្រួតពិនិត្យ និង កំណត់លក្ខខណ្ឌក្នុងការទទួលបាននូវជំនួយ
- កំណត់អទិភាពក្នុងការបញ្ជូនបន្ត
- បញ្ជូនអ្នកដែលមានសិទ្ធិទទួលយកសេវាកម្មគាំទ្រឲ្យទៅធ្វើការពិនិត្យឲ្យបានល្អិតល្អន់ជាបន្តទៀត
- សំរាំងនូវព័ត៌មានចាំបាច់ផ្តល់ទៅឲ្យសេវាកម្មជំនួយដោយមានការអនុញ្ញាតិពីអ្នកជំងឺ ដើម្បីចៀសវាងកុំឲ្យអ្នកជំងឺត្រូវផ្តល់ព័ត៌មានច្រំ ដែល។
- ធ្វើការអង្កេតលើការបញ្ជូនបន្ត ដើម្បីធានាឲ្យបានថា អ្នកជំងឺពិតជាទទួលបាននូវសេវាកម្មដែលគេត្រូវការ
- ផ្តល់ព័ត៌មានស្តីពីការគ្រប់គ្រងខ្លួនឯង នឹង បន្តទាក់ទងជាមួយនឹងអ្នកដែលត្រូវការចុះឈ្មោះសុំជំនួយ
- ផ្តល់នូវព័ត៌មានសុខភាពផ្លូវចិត្តទូទៅ និង ជួយបញ្ជូនបន្តទៅឲ្យសេវាកម្មដទៃទៀតតាមតម្រូវការចាំបាច់
- ប្រមូលផ្តុំការជ្រើសរើសគ្រែស្នាក់នៅក្នុងតំបន់សម្រាប់យុវជន និង សេវាកម្មផ្តល់ជំនួយដល់ការហូបចុកស្នាក់នៅ
- ធានាឲ្យបានថាការបញ្ជូនព័ត៌មានទៅឲ្យអ្នកផ្តល់ជំនួយ នឹងធ្វើឡើងលុះត្រាតែមានការអនុញ្ញាតិពីអ្នកជំងឺ

### តើខ្ញុំអាចទាក់ទងសេវាកម្មវាយតម្លៃមុននឹងធ្វើការទទួលយកបានតាមវិធីណា?

សម្រាប់អ្នកដែលរស់នៅក្នុងប៉ែកនិរតី ប៉ែកឦសាន ប៉ែកខាងជើង តំបន់ Bayside និង Frankston-Mornington Peninsula សូមទូរសព្ទមក Neami National ដែលមានលេខ **១៣០០ ៣៧៩ ៤៦២** (ពីម៉ោង ៩ព្រឹក ដល់ម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ)

សម្រាប់អ្នកដែលនៅតំបន់ខាងជើង ខាងកើត និងតំបន់អាគ្នេយ៍ សូមទូរសព្ទមក សុខភាពសហគម និង សង្គម **EACH** ដែលមានលេខ **១៣០០ ៧៨៥ ៣៥៨ (**ពីម៉ោង ៩ព្រឹក ដល់ម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ**)**

សម្រាប់អ្នកដែលនៅក្នុងតំបន់ Gippsland, Goulburn Valley, Grampians, Great South Coast, Hume និង Loddon Mallee សូមទូរសព្ទមក ACSO ដែលមានលេខ **១៣០០ ០២២ ៧៦០** (ពីម៉ោង ៩ព្រឹក ដល់ម៉ោង៥ល្ងាច ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ)

សូមមើលផែនទីនៅទំព័របន្ទាប់ ដែលបង្ហាញពីតំបន់ដែលស្ថិតក្រោម Neami National, EACH និង ACSO

### ព័ត៌មានបន្ថែម

www.health.vic.gov.au/mentalhealth/pdrss-reform

អស់រយៈពេល៣០ឆ្នាំមកហើយដែលអង្គការគាំទ្រសហគមអូស្រ្តាលី (ACSO) បានចាប់ដៃគូធ្វើការជាមួយនឹងសេវាកម្មសុខភាពនិងមនុស្សធម៌ ដើម្បីបង្កើននូវសុវត្ថិភាពចាត់បញ្ចូលសហគមឲ្យបានកាន់តែច្រើនដើម្បីចូលរួមដោះស្រាយនូវតម្រូវការដល់ក្រុមដែលមានភាពស្មុគ្រស្មាញ និង ចាញ់ប្រៀបគេ។ ឥរិយាបទរបស់ពួកយើងគឺ "បង្កើតឱកាសមួយទៀត" ហើយនិងវិធីសាស្រ្តដែលយើងធ្វើវាពណ៌នាពីតម្លៃរបស់ពួកយើង។

**www.acso.org.au**

EACH ប្រតិបត្តិការសេវាកម្មខុសៗគ្នាជាង១០០សេវាកម្ម នៅលើទីតាំង៣០កន្លែងក្នុងរដ្ឋ Victoria, New South Wales និង Queensland។ សេវាកម្មគំរូរបស់ EACH គឺផ្អែកលើការផ្តល់សេវាកម្មរួមបញ្ចូលគ្នា និង សន្តនិយម ដែលផ្តោតសំខាន់លើមនុស្សទាំងមូលក្នុងបរិបទនៃក្រុមគ្រួសារ និង សហគមរបស់ពួកគេ។

**www.each.com.au**

Neami National គឺជាសេវាកម្មសុខភាពផ្លូវចិត្តសហគមដែលគាំទ្រមនុស្សផ្អែកលើគុណតម្លៃ ភាពរឹងមាំ និង គោលដៅរបស់ពួកគេ។ យើងបាននិងកំពុងតែពង្រឹងសុខភាពផ្លូវចិត្តនិង សុខមាលភាពនៅក្នុងសហគមក្នុងតំបន់អស់រយៈពេលជាង២៧ឆ្នាំមកហើយ។

**www.neaminational.org.au**

នេះមិនមែនជាសេវាកម្មដោះស្រាយវិបត្តនោះ**ទេ។ ក្នុងករណីមាន គ្រោះអាសន្ន សូមទូរសព្ទលេខ** 000 (រថយន្តសង្រ្គោះបន្ទាន់ ប៉ូលិស អគ្គីភ័យ) ឬ លេខ ១៣ ១១ ១៤ (ខ្សែរទូរសព្ទបន្ទាន់សម្រាប់អ្នកមានវិបត្តក្នុងជីវិត)។

# INTAKE ASSESSMENT SERVICE FOR MENTAL HEALTH COMMUNITY SUPPORT SERVICES

